# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០២១

### កិច្ចសហការ អូស្ត្រាលី និងកម្ពុជា ដើម្បីពង្រឹងសុវត្ថិភាពការងារក្នុងវិស័យសំណង់នៅកម្ពុជា

ថ្ងៃនេះ ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ឯកឧត្តម Pablo Kang និង ឯកឧត្តម ឆាន់ សាផាន រដ្ឋលេខាធិការប្រចាំការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ដើម្បីដាក់ចេញជាផ្លូវការនូវកិច្ចសហប្រតិបត្តិការលើការពង្រឹងសុវត្ថិភាពការងារក្នុងវិស័យសំណង់នៅប្រទេសកម្ពុជា។

ឯកអគ្គរាជទូត Kang បានជួបជាមួយ ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មុននឹងពិធីចុះហត្ថលេខា ដើម្បីពិភាក្សាអំពីការគាំទ្រផ្នែកបច្ចេកទេសរបស់អូស្ត្រាលី នៅក្នុងវិស័យសំណង់ និងប្រធានបទនានា ទាក់ទងនឹងទំនាក់ទំនងទ្វេភាគីរវាងអូស្ត្រាលី និងកម្ពុជា។

ក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងនេះ អូស្ត្រាលីបាន និងកំពុងគាំទ្រ ក្រសួង ដើម្បីបង្កើតគោលការណ៍ណែនាំដំបូងមួយសម្រាប់កម្ពុជា ដែលផ្តោតទៅលើសុខភាព និងសុវត្ថិភាពនៅការដ្ឋានសំណង់ ដើម្បីពង្រឹងសុវត្ថិភាព និងកាត់បន្ថយហានិភ័យនៃការស្លាប់ និងគ្រោះថ្នាក់នានា នៅតាមការដ្ឋានសំណង់នៅកម្ពុជា។ ការងារលើគោលការណ៍ណែនាំនេះ បាននិងកំពុងដំណើរការយ៉ាងល្អ ហើយគោលការណ៍ណែនាំនេះ អាចនឹងបញ្ចប់ និងត្រូវបានដាក់ឱ្យអនុវត្តនៅចុងឆ្នាំ ២០២១។ អូស្ត្រាលី ក៏នឹងផ្តល់ការពង្រឹងសមត្ថភាពដល់ក្រុមការងារក្រសួង លើការត្រួតពិនិត្យ និងការពង្រឹងស្តង់ដារថ្មី ក៏ដូចជាការលើកកម្ពស់ការយល់ដឹង របស់វិស័យឯកជនអំពីទំនួលខុសត្រូវរបស់ពួកគេ ក្នុងការលើកកម្ពស់សុវត្ថិភាពការងារនៅការដ្ឋាន។

ឯកអគ្គរាជទូត Kang បានមានប្រសាសន៍ថា "ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃទីក្រុងនានានៅកម្ពុជា បានបង្កើតនូវបញ្ហាប្រឈមថ្មីៗបន្ថែមទៀត"។

"ការដួលរលំនៃអគារធំៗ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គឺជាសោកនាដកម្មនៅកម្ពុជា។ យើងមើលឃើញពីភាពចាំបាច់របស់អូស្ត្រាលី ក្នុងការឆ្លើយតបយ៉ាងឆាប់រហ័ស និង

ប្រកបដោយប្រសិទ្ធភាពទៅកាន់ សំណើសុំរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការគាំទ្រការធ្វើឱ្យប្រសើរឡើង នូវសុវត្ថិភាពរបស់កម្មករសំណង់ ក្រុមគ្រួសាររបស់ពួកគេ និងសាធារណជន រួមទាំងហានិភ័យនានា ទាក់ទងនឹងជំងឺកូវីដ-១៩" ។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ជា សុផារ៉ា បានមានប្រសាសន៍ថា "ចាប់តាំងពីប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីសំណង់ ដ៏មានសារៈសំខាន់ ក្នុងឆ្នាំ ២០១៩ មក យើងបាននិងកំពុងធ្វើការឥតឈប់ឈរលើការអនុវត្តច្បាប់នេះ។ ស្តង់ដារសុវត្ថិភាព ដែលអាចអនុវត្តបាននៅការដ្ឋានសំណង់ គឺជាការចាំបាច់ និងមានសារៈសំខាន់ ហើយយើងសូមសរសើរចំពោះការគាំទ្ររបស់អូស្ត្រាលី ដើម្បីឱ្យយើងអាចឈានទៅមុខយ៉ាងឆាប់រហ័ស"។

ជាផ្នែកមួយនៃជំនួយគាំទ្ររបស់អូស្ត្រាលី លើសុវត្ថិភាពការងារក្នុងវិស័យសំណង់ នៅឆ្នាំ ២០២០ អូស្ត្រាលី ក៏បានរៀបចំឱ្យក្រុមការងារមន្ត្រីកម្ពុជា ធ្វើដំណើរទៅប្រទេសអូស្ត្រាលី ដើម្បីរៀនសូត្រវគ្គខ្លី ស្តីពីសុវត្ថិភាពសំណង់ ដែលរួមទាំងការត្រួតពិនិត្យ ពីការអនុវត្តសុវត្ថិភាពក្នុងការដ្ឋានសំណង់ និងជួបជាមួយទីភ្នាក់ងារអូស្ត្រាលីនានា ដែលទទួលបន្ទុកផ្នែកត្រួតពិនិត្យបញ្ហាសុវត្ថិភាពសំណង់ផងដែរ។

ការគាំទ្រជាបន្តរបស់អូស្ត្រាលី ទៅលើសុវត្ថិភាពការងារក្នុងវិស័យសំណង់នេះ ជាផ្នែកមួយនៃកម្មវិធី "វិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ" របស់អូស្ត្រាលី ដែលមានរយៈពេល ៦ ឆ្នាំ និងមានទឹកប្រាក់ចំនួន ៩៩.៤ លានដុល្លារអូស្ត្រាលី។

**ទំនាក់ទំនងព័ត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au